ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃការចូលរួមសន្និសីទប្រធានសភានៃអន្តរសភា (ISC) នៅរដ្ឋធានីអ៊ីស្លាមម៉ាបាដ សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន

អគ្គលេខាធិការដ្ឋានរដ្ឋសភាមានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា ឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃរដ្ឋសភា និងជាអនុប្រធានសភាអន្តរជាតិដើម្បីភាពអត់ឱន និងសន្តិភាព (IPTP) តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា បានអញ្ជើញចូលរួម **«សន្និសីទប្រធានសភានៃអន្តរសភា»** ដែលបានរៀបចំឡើងនៅទីក្រុងអ៊ីស្លាមម៉ាបាដ កាលពីថ្ងៃទី១១-១២ ខែវិច្ឆិកា ឆ្នាំ២០២៥។

សន្និសីទនេះប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម **Syed Yousaf Raza Gilani** ប្រធានព្រឹទ្ធសភាប៉ាគីស្ថាន និងជាប្រធានស្ថាបនិកសន្និសីទប្រធានសភានៃអន្តរសភា និងឯកឧត្តម **Muhammad Shehbaz Sharif** នាយករដ្ឋមន្ត្រីប៉ាគីស្ថាន ព្រមទាំង ឯកឧត្តម លោកជំទាវជាប្រធានសភា អនុប្រធានសភា និងសមាជិកសភាមកពីជាង៤៥ប្រទេស ដោយបានផ្តោតលើការពិភាក្សាអំពីសន្តិភាព និងបញ្ហាសន្តិសុខដែលពិភពលោកកំពុងប្រឈម រួមទាំងសន្តិសុខប្រពៃណី និងសន្តិសុខមិនប្រពៃណី ដែលបានជះឥទ្ធិពលដល់ការអភិវឌ្ឍរបស់បណ្តាប្រទេសនានា និងសកលលោកទាំងមូល ព្រមទាំងរួមគ្នាស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមរួម ដោយប្រើប្រាស់យន្តការការទូតសភាបំពេញបន្ថែមដល់ការទូតប្រពៃណី។

ឯកឧត្តម **សួស យ៉ារ៉ា** ក៏បានលើកឡើងក្នុងអង្គសន្និសីទថាសន្តិភាពគឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍវិបុលភាព និងការរស់រានមានជីវិតរបស់មនុស្សជាតិ។ កម្ពុជាសម្រេចបានសន្តិភាពពេញលេញទូទាំងប្រទេសនៅចុងទសវត្សរ៍៩០ ក្រោមនយោបាយឈ្នះ-ឈ្នះរបស់ **សម្តេចតេជោ**។ ក្នុងន័យនេះ កម្ពុជាបានចែករំលែកមេរៀន និងបទពិសោធន៍ជាច្រើនក្នុងការកសាងសន្តិភាព និងការផ្សះផ្សាជាតិជូនទៅកាន់ពិភពលោកតាមរយៈការអនុម័ត**ធម្មនុញ្ញសន្តិភាពសកលៈ ដើម្បីមនុស្សជាតិ និងភពផែនដី** ដែលមានការគាំទ្រពីសភានៃ៦០ប្រទេសលើពិភពលោក ហើយត្រូវបានអន្តរសភាអាស៊ានទទួលស្គាល់ ជាគំនិតផ្តួចផ្តើមសន្តិភាព ដើម្បីពង្រឹងសាមគ្គីភាពជាសកល និងភាពជាដៃគូអភិវឌ្ឍន៍សម្រាប់វិបុលភាពរបស់មនុស្សជាតិ។ អង្គសន្និសីទ ក៏បានស្តាប់នូវសភាពការណ៍ថ្មីៗនៃជម្លោះព្រំដែនកម្ពុជា-ថៃ និងការដឹកនាំប្រកបដោយភាពអត់ធ្មត់ និងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា** ដើម្បីបញ្ចៀសសង្គ្រាម ការបាត់បង់អាយុជីវិតមនុស្ស និងការការពារខ្សែសង្វាក់ផ្គត់ផ្គង់នៅក្នុងតំបន់ ដោយគោរពតាមធម្មនុញ្ញអង្គការសហប្រជាជាតិ

វិមានរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៥ សារអេឡិចត្រូនិច:sg@na.gov.kh គេហទំព័រ: www.na.gov.kh

និងច្បាប់អន្តរជាតិ ដែលកំពុងអនុវត្តជាធរមាន។ កម្ពុជានៅរក្សាជំហរក្នុងការដោះស្រាយបញ្ហាដោយសន្តិវិធី ស្របតាមស្មារតីនៃសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួរ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ដើម្បីឈានទៅដល់ការបញ្ចប់ជម្លោះ និងកសាងសន្តិភាពរវាងប្រទេសទាំងពីរ។

អង្គសន្និសីទក៏បានចេញសេចក្តីថ្លែងការណ៍ «**អំពាវនាវឱ្យមានការគោរព និងការអនុវត្តពេញលេញនូវសេចក្តីប្រកាសរួមរវាងកម្ពុជា និងថៃ**» ដោយបានអំពាវនាវឱ្យកម្ពុជា-ថៃឱ្យគោរពយ៉ាងម៉ឺងម៉ាត់ និងអនុវត្តពេញលេញនូវគោលការណ៍ដែលបានឯកភាពគ្នានៅក្នុងសេចក្តីថ្លែងការណ៍រួម ដែលបានចុះហត្ថលេខានៅទីក្រុងគូឡាឡាំពួរកាលពីខែតុលាកន្លងទៅនេះ ហើយនឹងបន្តតាមដានការវិវត្តថ្មីៗនៃជម្លោះព្រំដែនកម្ពុជា-ថៃ ដោយយកចិត្តទុកដាក់ ហើយប្តេជ្ញាធ្វើការជាមួយសហគមន៍អន្តរជាតិដើម្បីដោះស្រាយការប្រឈមរួម និងលើកកម្ពស់គោលការណ៍នៃការពឹងពាក់គ្នាទៅវិញទៅមក វិបុលភាពរួម និងគុណតម្លៃរួមជាសកលដើម្បីសន្តិភាព សន្តិសុខ និងការអភិវឌ្ឍ។

ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមបានជួបពិភាក្សាការងារជាមួយគណៈប្រតិភូសភាបណ្តាប្រទេសជាមិត្ត ដូចជាប៉ាគីស្ថាន បេឡារុស ម៉ាល់ឌីវ អាស៊ែបៃហ្សង់ រុស្ស៊ីជាដើម ដើម្បីពង្រឹងចំណងមិត្តភាព ផ្លាស់ប្តូរយោបល់ និងជំរុញកិច្ចសហប្រតិបត្តិការទៅវិញទៅមក។

សន្និសីទប្រធានសភានៃអន្តរសភា (ISC) បានបិទបញ្ចប់ទៅដោយជោគជ័យប្រកបដោយភាតរភាព ក្រោមអធិបតីភាព ឯកឧត្តម **Asif Ali Zardari** ប្រធានាធិបតីប៉ាគីស្ថាន។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃសុក្រ ៩រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**